ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្តីប្រកាសព័ត៌មាន

នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១ តបតាមការអញ្ជើញរបស់ **ឯកឧត្តម ដាតូ លីម ចុក ហយ** (Dato Lim Jock Hoi) អគ្គលេខាធិការអាស៊ាន **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា រួមជាមួយរដ្ឋមន្ត្រីការបរទេស និងតំណាងនៃប្រទេសជាសមាជិកអាស៊ានផ្សេងទៀត បានអញ្ជើញចូលរួមក្នុងសន្និសីទដើម្បីកៀរគរជំនួយមនុស្សធម៌របស់អាស៊ានដល់មីយ៉ាន់ម៉ា តាមប្រព័ន្ធវីដេអូ។ តំណាងនៃប្រទេសដៃគូខាងក្រៅរបស់អាស៊ាន និងបណ្តាប្រទេសជាមិត្ត ក៏បានអញ្ជើញចូលរួមក្នុងសន្និសីទនេះផងដែរ។

លេខាធិការដ្ឋានអាស៊ាន និងមជ្ឈមណ្ឌលសម្របសម្រួលអាស៊ាន ដើម្បីជំនួយមនុស្សធម៌ និងការគ្រប់គ្រងគ្រោះមហន្តរាយ (AHA Centre) បានធ្វើបទបង្ហាញអំពីវិធីសាស្ត្រ២កម្រិត នៅក្នុងការផ្តល់ជំនួយមនុស្សធម៌ដល់ប្រទេសមីយ៉ាន់ម៉ា រួមមាន ការសង្គ្រោះជីវិត នៅដំណាក់កាលទី១ និង ការទ្រទ្រង់ជីវិត នៅដំណាក់កាលទី២ ។ សន្និសីទបានសង្កត់ធ្ងន់អំពីការដឹកជញ្ជូនជំនួយជាបន្ទាន់ និងដែលមានការសម្របសម្រួលយ៉ាងល្អ ទៅកាន់សេវាសុខាភិបាលនៅមីយ៉ាន់ម៉ា ដើម្បីទប់ស្កាត់ការរីករាលដាលនៃវីរុស និងផ្តល់ការថែទាំចាំបាច់ដល់អ្នកដែលបានឆ្លងជំងឺ និងដើម្បីជួយសម្រាលការលំបាកនៃសហគមន៍នានាដែលងាយរងគ្រោះ និងនៅតំបន់ដាច់ស្រយាល។ អ្នកចូលរួមនៅក្នុងសន្និសីទ បានសម្តែងនូវការគាំទ្រចំពោះកិច្ចខិតខំប្រឹងប្រែងរបស់អាស៊ាន ក្នុងការកៀរគរជំនួយមនុស្សធម៌សម្រាប់មីយ៉ាន់ម៉ា ស្របទៅតាមចំណុចទី៤ នៃការព្រមព្រៀងជាឯកច្ឆន្ទ ៥ចំណុច ដែលត្រូវបានសម្រេចនៅក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំអាស៊ាន កាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២១។ អង្គសន្និសីទ បានធ្វើការសន្យាចូលរួមចំណែកជាមួយកញ្ចប់ហិរញ្ញវត្ថុដ៏សំខាន់ និងជំនួយសប្បុរស រួមមានវ៉ាកសាំង ជាដើម ដោយផ្តោតជាសំខាន់សម្រាប់ដំណើរប្រតិបត្តិការនៃជំនួយនៅដំណាក់កាលទី១។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** បានជម្រាបជូនអង្គសន្និសីទអំពីការចូលរួមចំណែករបស់កម្ពុជា ជាថវិកាចំនួន១០០.០០០ (១០ម៉ឺន) ដុល្លារអាមេរិក ដើម្បីគាំទ្រជំនួយមនុស្សធម៌ដល់ប្រទេសមីយ៉ាន់ម៉ា តាមរយៈមជ្ឈមណ្ឌលសម្របសម្រួលអាស៊ាន ដើម្បីជំនួយមនុស្សធម៌ និងការគ្រប់គ្រងគ្រោះមហន្តរាយ (AHA Centre)។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានរំលឹកផងដែរអំពីការជួយឧបត្ថម្ភគាំទ្រយ៉ាងឆាប់រហ័សរបស់កម្ពុជាដល់កិច្ចខិតខំប្រឹងប្រែងរបស់មីយ៉ាន់ម៉ា ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ រួមមាន ម៉ាស់ ចំនួន២លាន និងឧបករណ៍វេជ្ជសាស្ត្រមួយចំនួន



អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល : mfaic@mfaic.gov.kh

ដែលបានផ្តល់កាលពីខែវិច្ឆិកា ឆ្នាំ២០២០ និងការរួមចំណែកបន្ថែមទៀតនៅមុនពេលនៃសន្និសីទនេះ រួមមាន ជាថវិកាចំនួន២០០.០០០ (២០ម៉ឺន) ដុល្លារអាមេរិក និងជាឧបករណ៍វេជ្ជសាស្ត្រ ដូចជា ម៉ាស់ចំនួន៣លាន ឧបករណ៍ធ្វើតេស្តរហ័សចំនួន៥០០.០០០ សំលៀកបំពាក់សុវត្ថិភាព PPE ចំនួន២.០០០ឈុត ម៉ាស៊ីនផលិតអុកស៊ីហ្សែនស្វ័យប្រវត្តិ ចំនួន១០០គ្រឿង ម៉ាស៊ីនជំនួយដកដង្ហើមចំនួន២០គ្រឿង និងម៉ាស៊ីនតាមដានសញ្ញាជីវិតចំនួន២០គ្រឿង ដែលបានបញ្ជូនទៅដល់នៅថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០២១។ បន្ថែមលើនេះ កាកបាទក្រហមកម្ពុជា ក៏នឹងបរិច្ចាគថវិកា ចំនួន ១០០.០០០ (១០ម៉ឺន) ដុល្លារអាមេរិក ដល់សង្គមកាកបាទក្រហមមីយ៉ាន់ម៉ា (Myanmar Red Cross Society) ផងដែរ៕

ថ្ងៃព្រហស្បតិ៍ ១១កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១